UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស

# ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព

## ក. ប្រភេទហិរញ្ញប្បទាន

**ហិរញ្ញប្បទាននេះគឺផ្តល់ជូនសម្រាប់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី**

និងជនមិនស្ថិតក្នុងភេទណាមួយនៃភេទទាំងពីរកំណត់តាមបែបប្រពៃណី[1] និងអង្គការក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលមានសេចក្តីត្រូវការបន្ទាន់ ឬស្ថិតក្នុងគ្រោះអាសន្នពាក់ព័ន្ធជាមួយសុវត្ថិភាព ឬសុខុមាលភាពរបស់ខ្លួន។ ហិរញ្ញប្បទាននេះមានចេតនាផ្តល់ជូនសម្រាប់មនុស្ស ឬអង្គការដែលកំពុងរងការគំរាមកំហែង ឬស្ថិតក្នុងស្ថានភាពអាសន្ន វិបត្តិ ឬហានិភ័យបណ្តាលមកពីការងាររបស់ខ្លួនក្នុងការការពារសិទ្ធិស្ត្រី និងសិទ្ធិមនុស្ស។ ហិរញ្ញប្បទាននេះក៏មានផ្តល់ជូនសម្រាប់សេចក្តីត្រូវការក្នុងគ្រាបន្ទាន់សម្រាប់សុខុមាលភាព ដូចជាការប្រឹក្សាយោបល់ផ្នែកចិត្តសង្គម ការព្យាបាលសម្រាប់ការប៉ះទង្គិចធ្ងន់ធ្ងរ ឬការជួយជ្រោមជ្រែងផ្នែកវេជ្ជសាស្ត្រ។

## ខ. ការដាក់ពាក្យស្នើសុំ

សូមដាក់ពាក្យអនឡាញ នៅក្នុងគេហទំព័រ www.uafanp.org ឬអ៊ីមែលមកកាន់អាសយដ្ឋាន grants@uafanp.org

## គ. លក្ខខណ្ឌវិនិច្ឆ័យហិរញ្ញប្បទាន

១. ស្ត្រី ឬដឹកនាំដោយស្ត្រី៖ អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ឬជនមិនស្ថិតក្នុងភេទណាមួយនៃភេទទាំងពីរកំណត់តាមបែបប្រពៃណី ចាំបាច់ត្រូវតែជាអ្នកទទួលផលចម្បងអំពីហិរញ្ញប្បទាន ដោយជាការល្អគួរត្រូវបានបញ្ជូនតាមបណ្តាញអង្គការសិទ្ធិស្ត្រី។

២. ផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្ស៖ អ្នកការពារសិទ្ធិ ឬអង្គការដែលលើកកម្ពស់ការឈានទៀងនៃសិទ្ធិរបស់ស្ត្រី និង/ឬអ្នកស្រឡាញ់ភេទដូចគ្នា ដោយប្រើប្រាស់យុទ្ធវិធី ឬយុទ្ធសាស្ត្រអហិង្សា និងលើកកម្ពស់ភាពជាសកលនៃសិទ្ធិមនុស្ស។

៣. មិនបានរំពឹងទុកជាមុន និង/ឬក្នុងពេលបន្ទាន់៖ ព្រឹត្តិការណ៍ ឬស្ថានភាពជាក់លាក់ដែលត្រូវឆ្លើយតប គឺជាស្ថានភាពអាសន្ន ឬវិបត្តិដែលអ្នកការពារសិទ្ធិ ឬស្ថាប័នរបស់ពួកគេកំពុងប្រឈមហានិភ័យ។

៤. គាំទ្រសម្រាប់សន្តិសុខ និងសុខុមាលភាព៖ ហិរញ្ញប្បទានដែលត្រូវបានស្នើសុំចាំបាច់ត្រូវតែចាត់ចែងទុកសម្រាប់វិធានការសន្តិសុខ (ឧ. ជំនួយផ្នែកច្បាប់ ការផ្លាស់ទីតាំង ឬការជន្លៀសចេញ ការវាយតម្លៃហានិភ័យ និងការបណ្តុះបណ្តាល ឧបករណ៍សន្តិសុខ) និង/ឬសម្រាប់សេចក្តីត្រូវការផ្នែកសុខុមាលភាព (ឧ. ការប្រឹក្សាយោបល់ផ្នែកចិត្តសាស្ត្រ ការព្យាបាលបញ្ហាការប៉ះទង្គិចធ្ងន់ធ្ងរផ្លូវចិត្ត ជំនួយផ្នែកវេជ្ជសាស្ត្រ) ជូនដល់អ្នកការពារ ឬស្ថាប័នរបស់ពួកគេ

៥. ក្នុងពេល ឬភ្លាមៗក្រោយពេលវិបត្តិ៖ ហិរញ្ញប្បទានដែលត្រូវបានស្នើសុំ ចាំបាច់ត្រូវមានចេតនា ដើម្បីគាំទ្រដល់សន្តិសុខ និងសុខុមាលភាពរបស់អ្នកការពារសិទ្ធិ ឬស្ថាប័នរបស់ពួកគេក្នុងពេលមានវិបត្តិ ឬភ្លាមៗក្រោយពេលមានវិបត្តិ។

៦. បានទទួលការគាំទ្រ ឬស្ថិតក្នុងបណ្តាញ៖ អ្នកការពារសិទ្ធិ ឬអង្គការរបស់ពួកគេ មានការគាំទ្រពីអ្នកដទៃទៀតដែលជាប់ពាក់ព័ន្ធ ក្នុងផ្នែកសិទ្ធិមនុស្សរបស់ស្ត្រី សិទ្ធិផ្លូវភេទ ឬវិស័យសិទ្ធិមនុស្សពាក់ព័ន្ធ នៅថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ។

### យើងមិនផ្តល់មូលនិធិសម្រាប់៖

- ជនមានភេទជាបុរសតាមការកំណត់ទូទៅ[2] ឬអង្គការ ឬបណ្តាញដឹកនាំដោយបុរស
- សំណើសុំជាលក្ខណៈបុគ្គលដោយមិនមានការគាំទ្រពីស្ថាប័នណាមួយ។ សហគមន៍ដែលបានបង្កើតរឹងមាំហើយ ឬសម្ព័ន្ធភាពបណ្តាញដែលបានបង្កើតរឹងមាំហើយ ឬទីប្រឹក្សា របស់ UAF A&P
- សកម្មភាព ឬគម្រោងសម្រាប់វិបត្តិមនុស្សធម៌ ឬគ្រោះមហន្តរាយធម្មជាតិ
- សកម្មភាព ឬគម្រោងផ្តោតការយកចិត្តទុកដាក់លើជំនួយអភិវឌ្ឍន៍ ឬជំនួយសប្បុរសធម៌
- គម្រោង ឬសកម្មភាពដែលជាផ្នែកមួយនៃកម្មវិធីបន្តរបស់ស្ថាប័នណាមួយ
- ថវិកាប្រតិបត្តិការជាប្រចាំ និង/ឬមូលនិធិបិទភ្ជិតគម្លាត (ឬដើម្បីបំពេញគម្លាតមូលនិធិ)។

## ឃ. បណ្តាញប្រាស្រ័យទាក់ទងមានសន្តិសុខ៖

UAF A&P ជឿជាក់ថាសន្តិសុខ និងឯកជនភាពរបស់អ្នកដាក់ពាក្យ និងអ្នកទទួលហិរញ្ញប្បទានរបស់យើងគឺមានសារៈសំខាន់ណាស់ចំពោះកម្មវិធីផ្តល់ហិរញ្ញប្បទានការឆ្លើយតបរហ័សរបស់យើង។ មួយផ្នែកនៃការប្តេជ្ញាចិត្តនេះ គឺយើងត្រូវធានាយ៉ាងណាឱ្យយើងអាចប្រើប្រាស់បណ្តាញប្រាស្រ័យទាក់ទងដែលមានសន្តិសុខ និងនិងមានសុវត្ថិភាព (encrypt)។ ខាងក្រោមនេះគឺជាទម្រង់នៃបណ្តាញឆ្លើយឆ្លងគ្នាតែមួយគត់នៅក្នុងការប្រាស្រ័យទាក់ទងដែលយើងទទួលស្គាល់:

- សម្រាប់អ៊ីមែលត្រូវប្រើកម្មវិធី, ProtonMail https://protonmail.com/signup
- សម្រាប់ការផ្ញើសារត្រូវប្រើកម្មវិធី, Signal application https://signal.org

---

1 ជនមិនស្ថិតក្នុងភេទណាមួយនៃភេទទាំងពីរកំណត់តាមបែបប្រពៃណី គឺជាសព្ទមានន័យក្តោបរួមទូទៅ សំដៅលើបុគ្គលទាំងឡាយណាដែលអត្តសញ្ញាណយេនឌ័រ និង/ឬការបង្ហាញចេញផ្នែកយេនឌ័ររបស់ពួកគេគឺមិនមែនជាបុរសទាំងស្រុង ឬជាស្ត្រីទាំងស្រុង មិនមានលក្ខណៈជាប្រុស ឬជាស្រីដាច់ខាត ជាហេតុធ្វើឱ្យពួកគេស្ថិតនៅក្រៅចំណាត់ប្រភេទយេនឌ័រក្នុងចង្កោមភេទទាំងពីរដែលបានកំណត់តាមបែបប្រពៃណី និងនិយាមដែលកំណត់ថាជាភេទធម្មតា។ UAF A&P ប្រើប្រាស់ពាក្យនេះ ដើម្បីក្តោបទូទៅលើអ្នកមានអវយវៈភេទទាំងពីរនៅរួមគ្នាក្នុងបុគ្គលតែមួយ អ្នកមានពហុយេនឌ័រ អ្នកមានយេនឌ័រមិនអាចកំណត់បាន អ្នកមានយេនឌ័រប្រែប្រួល និងអ្នកគតមានយេនឌ័រ។

2 ជនមានភេទជាបុរសតាមការកំណត់ទូទៅ គឺជាបុគ្គលដែលកំណត់អត្តសញ្ញាណខ្លួនឯងថាជាបុរស ហើយត្រូវបានកំណត់ថាជាបុរសភេទតាំងពីកំណើត។

UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស

**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

យើងសូមផ្តល់អនុសាសន៍ឱ្យអ្នកត្រូវបង្កើតគណនីនៅក្នុងបណ្តាញប្រាស្រ័យទាក់ទងខាងលើ រួចប្រើគណនីទាំងនេះដើម្បីប្រាស្រ័យទងជាមួយយើង។ ការចុះឈ្មោះបង្កើតគណនីដើម្បីប្រើកម្មវិធីទាំងនេះចំណាយពេលត្រឹមតែ ១០ នាទីប៉ុណ្ណោះ។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបង្កើតគណនីមានសុវត្ថិភាពទាំងនេះ សូមផ្ញើអ៊ីមែល មកកាន់ Esther ដែលជាអ្នកសម្របសម្រួលគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់យើងតាមអ៊ីមែល esther@uafanp.org ។

## I. ព័ត៌មានសម្រាប់ទំនាក់ទំនង

| | |
|---|---|
| ឈ្មោះអ្នកធ្វើសំណើ៖ ឈ្មោះអង្គការ | |
| ឬបណ្តាញ /សម្ព័ន្ធភាពសហគមន៍ (ចាំបាច់ត្រូវមានអង្គការ / បណ្តាញ ឬ អ្នកឧបត្ថម្ភដើម្បីអាចមានលក្ខណសម្បត្តិទទួលបានហិរញ្ញប្បទាន) | |
| មុខតំណែង | |

| | | | | |
|---|---|---|---|---|
| អាសយដ្ឋានប្រៃសណីយ៍ | អាសយដ្ឋាន | | | |
| | ក្រុង | ខេត្ត/ក្រុង | ប្រទេស | លេខកូដប្រៃសណីយ៍ |

| | | | |
|---|---|---|---|
| ព័ត៌មានសម្រាប់ទំនាក់ទំនង | អ៊ីមែល | ទូរសព្ទចល័ត | |
| | ទូរសព្ទ | អាសយដ្ឋាន Signal | អាសយដ្ឋាន WhatsApp |

| | | |
|---|---|---|
| គេហទំព័រ និងបណ្តាញផ្សព្វផ្សាយសង្គម (ប្រសិនបើមាន) | គេហទំព័រ | Facebook |
| | Twitter | ផ្សេងទៀត |

| | |
|---|---|
| ២. តើអ្នកធ្វើសំណើសម្រាប់ខ្លួនឯង ឬសម្រាប់អង្គការរបស់អ្នក ឬតាងនាមឱ្យនរណាម្នាក់ផ្សេងទៀត/អង្គការដទៃ? | ◉ សម្រាប់ខ្លួនខ្ញុំ ឬអង្គការរបស់ខ្ញុំ (ប្រសិនបើគូសជ្រើសរើសចម្លើយនេះ សូមរំលងសំណួរទី៣, ៣ក និង ៣ខ)<br>○ តាងនាមឱ្យបុគ្គល ឬអង្គការដទៃ (ប្រសិនបើគូសយកចម្លើយនេះសូមបំពេញសំណួរទី៣, ៣ក ឬ ៣ខ) |

៣. ប្រសិនបើអ្នកកំពុងធ្វើសំណើនេះតាងនាមឱ្យបុគ្គលដទៃក្រៅពីខ្លួនឯង ឬសម្រាប់អង្គការ /បណ្តាញ/សហគមន៍ដទៃផ្សេងទៀតសូមសរសេរឈ្មោះមនុស្ស អង្គការ ឬបណ្តាញ/សហគមន៍នោះនៅខាងក្រោម។ (សូមរំលងសំណួរនេះប្រសិនបើអ្នកមិនបំពេញពាក្យស្នើសុំនេះសម្រាប់មនុស្ស អង្គការ ឬបណ្តាញ /សហគមន៍ដទៃក្រៅពីខ្លួនឯង)

| | | |
|---|---|---|
| ៣ក. តាងនាមឱ្យអ្នកទទួលផលជាបុគ្គល | ឈ្មោះបុគ្គល | |
| | អ៊ីមែល | លេខទូរសព្ទ |

URGENT ACTION FUND FOR WOMEN'S HUMAN RIGHTS ASIA & PACIFIC

UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស

**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

| | | |
|---|---|---|
| ៣ខ. តាងនាមឱ្យអ្នកទទួលផល | ឈ្មោះបណ្តាញ ឬអង្គការ | |
| | ឈ្មោះបុគ្គលទំនាក់ទំនង | |
| | អ៊ីមែល | ទូរសព្ទ |

## II. ព័ត៌មានអំពីស្ថាប័ន

### ១. បេសកកម្ម និងគោលដៅរបស់អង្គការ ឬបណ្តាញ៖

**១ក. វិស័យជំនាញឯកទេស៖**

- ☐ សិទ្ធិពលរដ្ឋ និងនយោបាយ
- ☐ ការប្រែប្រួលអាកាសធាតុ / យុត្តិធម៌បរិស្ថាន
- ☐ ជម្លោះ/ការកសាងសន្តិភាព
- ☐ សន្តិសុខឌីជីថល/ICT
- ☐ ជនភាគតិច
- ☐ ការជម្លៀសចេញដោយបង្ខំ/IDPs
- ☐ ការសះជា និង/ឬ សុខុមាលភាព
- ☐ មេរោគអេដស៍/ជំងឺអេដស៍
- ☐ សិទ្ធិមនុស្ស
- ☐ ជនជាតិដើមភាគតិច
- ☐ សិទ្ធិការងារ
- ☐ សិទ្ធិដីធ្លី
- ☐ ប្រព័ន្ធច្បាប់/ប្រព័ន្ធយុត្តិធម៌
- ☐ អ្នកស្រឡាញ់ភេទដូចគ្នា/សូជី
- ☐ សិទ្ធិជនទេសន្តរប្រវេសន៍
- ☐ កសិករ/ស្ត្រីជនបទ
- ☐ ជនមានពិការភាព
- ☐ ការចូលរួមផ្នែកនយោបាយ
- ☐ ជនភៀសខ្លួន/ជនគ្មានរដ្ឋ
- ☐ ជនភាគតិចផ្នែកសាសនា
- ☐ ពលរដ្ឋវ័យចាស់
- ☐ អ្នកប្តូរភេទ
- ☐ សុខភាព និងសិទ្ធិផ្លូវភេទ និងសុខភាព និងសិទ្ធិបន្តពូជ (SRHR)
- ☐ យុត្តិធម៌សង្គម និងយុត្តិធម៌/សិទ្ធិសេដ្ឋកិច្ច
- ☐ ការជួញដូរ
- ☐ អ្នកក្រីក្រនៅទីប្រជុំជន/អ្នកតាំងលំនៅក្នុង ទីប្រជុំជនមិនរៀបរយ
- ☐ អំពើហិង្សាប្រឆាំងស្ត្រី/អំពើហិង្សាផ្នែកលើយេនឌ័រ
- ☐ សិទ្ធិមនុស្សរបស់ស្ត្រី
- ☐ អ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី
- ☐ យុវជន/ស្ត្រីវ័យក្មេង

ផ្សេងទៀត៖

UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស
**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

## ២.អ្នកធ្វើការសម្រេចចិត្តសំខាន់ៗ និងសមាសភាពយេនឌ័រ

| | ឈ្មោះបុគ្គលទំនាក់ទំនង | តំណែង | អត្តសញ្ញាណយេនឌ័រ |
|---|---|---|---|
| តើនរណាជាអ្នកធ្វើការសម្រេចចិត្តចម្បងនៅក្នុងអង្គការ/បណ្តាញ /សហគមន៍របស់អ្នក? | ១. | | |
| | ២. | | |
| | ៣. | | |

## ៣. បុគ្គលធានា/អ្នកឧបត្ថម្ភ

| | | |
|---|---|---|
| សូមផ្តល់ឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកធានាយ៉ាងហោចណាស់ពីរនាក់ដែលអាចគាំទ្រគាំទ្រការងាររបស់អ្នក។ ជាការល្អ អ្នកគួរជម្រាបប្រាប់ពួកគាត់ឱ្យបានដឹងជាមុនដើម្បីឱ្យពួកគាត់អាចផ្តល់ការឆ្លើយតបយ៉ាងទាន់ពេលវេលា។ | ១. ឈ្មោះអ្នកធានា | ឈ្មោះអង្គការ / សម្ព័ន្ធភាពបណ្តាញ |
| | អ៊ីមែល | ទូរសព្ទ |
| | ទំនាក់ទំនងជាមួយអ្នកដាក់ពាក្យ (តើអ្នកស្គាល់បុគ្គលនេះដោយរបៀបណា)៖ | |
| | ២. ឈ្មោះអ្នកធានា | ឈ្មោះអង្គការ / សម្ព័ន្ធភាពបណ្តាញ |
| | អ៊ីមែល | ទូរសព្ទ |
| | ទំនាក់ទំនងជាមួយអ្នកដាក់ពាក្យ (តើអ្នកស្គាល់បុគ្គលនេះដោយរបៀបណា)៖ | |

## ៤. ការគាំទ្ររបស់ម្ចាស់ជំនួយ៖

| | | |
|---|---|---|
| រាយឈ្មោះអ្នកផ្តល់មូលនិធិនាពេលបច្ចុប្បន្ន ឬអ្នកផ្តល់មូលនិធិកន្លងមកចំនួន ១-២ (ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ) និងព័ត៌មានសម្រាប់ទំនាក់ទំនងរបស់ពួកគេ។ | ១. ឈ្មោះអ្នកផ្តល់មូលនិធិ | |
| | អ៊ីមែល | ទូរសព្ទ |
| | ២. ឈ្មោះអ្នកផ្តល់មូលនិធិ | |
| | អ៊ីមែល | ទូរសព្ទ |

UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស
**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

## ៥. វិធីសាស្ត្រនៃការបញ្ជូនមកកាន់ UAF A&P

| | | |
|---|---|---|
| តើអ្នកបានដឹងអំពី UAF ឬ UAF A&P ដោយរបៀបណា?សូមគូសយកចម្លើយទាំងអស់ដែលត្រូវ។ | ☐ ការស្រាវជ្រាវតាមអ៊ីនធឺណែត/គេហទំព័រ UAF A&P<br>☐ បណ្តាញផ្សព្វផ្សាយសង្គម<br>☐ បញ្ជើអសយដ្ឋានអ៊ីមែល/គ្រុប<br>☐ ធ្លាប់បានទទួលមូលនិធិ/ហិរញ្ញប្បទានពីមុនមក (UAF A&P)<br>☐ ទីប្រឹក្សា UAF A&P | ☐ បុគ្គលិករបស់ UAF A&P<br>☐ សហការី/មិត្តភក្តិ<br>☐ ដាក់ពាក្យស្នើសុំកន្លងមក ប៉ុន្តែពុំបានទទួលមូលនិធិ (មិនមែនអ្នកទទួលហិរញ្ញប្បទានពី UAF A&P)<br>☐ ផ្សេងទៀត |

## III. សំណួរស្តីអំពីសំណើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព(ចាំបាច់ត្រូវតែផ្តល់ចម្លើយ)

សំនួរមគ្គុទេសក៍៖ សំណួរមគ្គុទេសក៍ទាំងនេះនឹងជួយអ្នកក្នុងការកំណត់ថាតើអ្នកគួរតែបំពេញសំណើរសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាពឬទេ។ ប្រសិនបើអ្នកឆ្លើយ ចាស ចំពោះសំណួរណាមួយខាងក្រោមសូមបំពេញសំណួរទី ១-១០ នៅផ្នែកខាងក្រោម។

- តើអ្នក (និង/ឬគ្រួសារ អ្នករួមការងារ ឬបុគ្គលិក អង្គការ (បច្ចុប្បន្នកំពុងរងការគំរាមកំហែង ការវាយប្រហារ ឬគ្រោះថ្នាក់ដែលច្បាស់ជានឹងកើតមានចំពោះសុខភាព ឬជីវិតរបស់អ្នកអាស្រ័យដោយការងារជាសកម្មជនសិទ្ធិមនុស្សរបស់អ្នកឬទេ?
- តើអ្នកកំពុងស្នើសុំមូលនិធិដើម្បីផ្លាស់ទីតាំង ឬជម្លៀសចេញទៅកាន់ទីតាំងសុវត្ថិភាពឬទេ?
- តើអ្នកកំពុងស្នើសុំមូលនិធិដើម្បីបង្កើនវិធានការសន្តិសុខនៅការិយាល័យ ឬផ្ទះរបស់អ្នក (ហេដ្ឋារចនាសម្ព័ន្ធ បុគ្គលិកសន្តិសុខដែលមិនបំពាក់បំពាក់អាវុធ បច្ចេកវិទ្យាសន្តិសុខឌីជីថល) ឬទេ?
- បន្ថែមលើវិធានការសន្តិសុខណាមួយដូចបានបញ្ជាក់ខាងលើ តើអ្នកកំពុងស្នើសុំមូលនិធិសម្រាប់ការគាំទ្រផ្នែកច្បាប់ ការគាំទ្រពេលកំពុងស្ថិតនៅក្នុងការឃុំឃាំង ការស្តារនីតិសម្បទា (ការគាំទ្រផ្នែកចិត្តសាស្ត្រ ឬការគាំទ្រសម្រាប់ការប៉ះទង្គិចធ្ងន់ធ្ងរ) ការគាំទ្រសម្រាប់គ្រួសារ ឬការគាំទ្រផ្សេងទៀតដែលពុំបានបញ្ជាក់ខាងលើឬទេ?
- តើអ្នកកំពុងស្នើសុំមូលនិធិសម្រាប់សេចក្តីត្រូវការផ្នែកសុខុមាលភាពផ្សេងទៀតដែលពុំបានរៀបរាប់ខាងលើឬទេ?

| | |
|---|---|
| ១. សូមពណ៌នាដោយសង្ខេបអំពីការងារជាសកម្មជនរបស់អ្នកនៅក្នុងការជម្រុញ និងការពារសិទ្ធិរបស់ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា (ឬបុគ្គល/អង្គការ/បណ្តាញ / សហគមន៍ដែលអ្នកកំពុងដាក់ពាក្យតាងនាមឱ្យពួកគេ) | |
| *២ក. សូមពិពណ៌នាអំពីហានិភ័យ និងការគំរាមកំហែងដែលអ្នក ឬអង្គការ /បណ្តាញ/សហគមន៍របស់អ្នកកំពុងជួបប្រទះ។ (ប្រសិនបើអាចសូមដាក់បញ្ចូលតំណភ្ជាប់ទៅកាន់អត្ថបទសារព័ត៌មាន ឬការផ្សាយតាមបណ្តាញផ្សព្វផ្សាយ)។* | |

UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស

**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

| | |
|---|---|
| ២២. សូមគូសជ្រើសយករាល់ការរំលោភបំពានសិទ្ធិមនុស្សដែលត្រូវសម្រាប់ស្ថានភាពរបស់អ្នក ឬអង្គការរបស់អ្នក។ | I. ការវាយប្រហារមកលើជីវិត សុចរិតភាពផ្នែករាងកាយ និងផ្លូវចិត្ត<br>☐ ការសម្លាប់ និងការប៉ុនប៉ងសម្លាប់<br>☐ ការបាត់ខ្លួន<br>☐ ការធ្វើទារុណកម្ម<br>☐ ការប្រព្រឹត្តដោយឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក<br>☐ ការរំលោភសេពសន្ថវៈ ការធ្វើបាបផ្លូវភេទ និងការរំលោភបំពាន<br>☐ អំពើហិង្សាក្នុងគ្រួសារ ការប្រើប្រាស់កម្លាំងហួសប្រមាណ<br>☐ ផ្សេងទៀត |
| | II. ការដកហូតសេរីភាពផ្លូវកាយ និងផ្លូវចិត្ត<br>☐ ការឃាត់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត<br>☐ ការឃុំខ្លួនផ្នែករដ្ឋបាល<br>☐ ការចាប់ជំរិត/ការចាប់ពង្រត់<br>☐ ការឃុំឃាំងនៅមណ្ឌលវិកលចរិត<br>☐ ផ្សេងទៀត |
| | III. ការវាយប្រហារមកលើភាពជាបុគ្គល និងកេរ្តិ៍ឈ្មោះ<br>☐ ការគំរាម ការព្រមាន និងការដាក់ឱសានវាទ<br>☐ Psychological harassment<br>☐ ការគម្រាមបើកបង្ហាញរឿងអាស្រូវ និងការសម្លុតជម្រិតដើម្បីទារប្រាក់<br>☐ ការបៀតបៀនផ្លូវភេទ<br>☐ ការដាក់នុយផ្នែកយេនឌ័រ និងផ្លូវភេទ<br>☐ ការនិយាយអាស្រូវ ការពោលបង្ខូចឈ្មោះ ការលាបពណ៌ យុទ្ធនា ការធ្វើឱ្យអាម៉ាស់<br>☐ ការប្រើសម្តីស្អប់ខ្ពើម<br>☐ ការមាក់ងាយ ការមាក់ងាយ ការញែកឱ្យនៅដាច់តែឯង និងការនិរទេស<br>☐ ផ្សេងទៀត |
| | IV. ការឈ្លានពានលើឯកជនភាព និងការបំពាននានាដែលជាប់ពាក់ព័ន្ធជាមួយទំនាក់ទំនងផ្ទាល់ខ្លួន<br>☐ ការចុះឆែកឆេរការិយាល័យ ឬផ្ទះ<br>☐ ការវាយប្រហារ និងការបំភិតបំភ័យសមាជិកគ្រួសារ និងសមាជិកសហគមន៍<br>☐ ផ្សេងទៀត |

| | |
|---|---|
| | V. បទបញ្ញត្តិ និងការអនុវត្តផ្ទុកច្បាប់ដែលរឹតបន្តឹងដល់ការងារជាសកម្មជនរបស់បុគ្គលជាស្ត្រី និងបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រមិនអនុលោមតាមការកំណត់តាមបែបប្រពៃណី<br>☐ ការប្រើប្រាស់ច្បាប់ទំនៀមទម្លាប់ និងក្របខណ្ឌច្បាប់តឹងរ៉ឹង ហួសប្រមាណផ្អែកលើមូលដ្ឋាន សាសនា<br>☐ ការចាត់ទុកជាបទល្មើស និងការកាត់ទោស<br>☐ ការស៊ើបអង្កេត ការសួរចម្លើយ ការឈ្លបតាមដាន និងការដាក់ចូលបញ្ជីខ្មៅដោយខុសច្បាប់<br>☐ ច្បាប់ដែលត្រូវបានបង្កើតឡើងប្រឆាំងជាមួយអង្គការមិនមែនរដ្ឋាភិបាល<br>☐ ការដាក់ទណ្ឌកម្មនៅក្នុងកន្លែងធ្វើការ<br>☐ ផ្សេងទៀត ________ |

| | |
|---|---|
| ២ខ. សូមគូសជ្រើសយករាល់ការរំលោភបំពានសិទ្ធិមនុស្សដែលត្រូវសម្រាប់ស្ថានភាពរបស់អ្នក ឬអង្គការរបស់អ្នក។ | VI. ការរំលោភបំពានសេរីភាពបញ្ចេញមតិ សេរីភាពជាសមាគម និងសេរីភាពក្នុងការប្រមូលផ្តុំរបស់ស្ត្រី<br>☐ ការរឹតបន្តឹងលើសេរីភាពសមាគម<br>☐ ការរឹតបន្តឹងលើសិទ្ធិទទួលបានមូលនិធិ<br>☐ ការរឹតបន្តឹងលើសេរីភាពក្នុងការបញ្ចេញមតិ<br>☐ ការរឹតបន្តឹងលើលទ្ធភាពទទួលបានព័ត៌មាន<br>☐ ការរឹតបន្តឹងលើការប្រាស្រ័យទាក់ទងជាមួយស្ថាប័នអន្តរជាតិ<br>☐ ការរឹតបន្តឹងលើសេរីភាពក្នុងការប្រមូលផ្តុំ<br>☐ ផ្សេងទៀត ________ |
| | VII. ការរឹតបន្តឹងផ្អែកយេនឌ័រទៅលើសេរីភាពក្នុងការផ្លាស់ទី<br>☐ ការតម្រូវឱ្យសុំការអនុញ្ញាត ឬការបដិសេធមិនឱ្យធ្វើដំណើរទៅក្រៅប្រទេស<br>☐ ការរឹតបន្តឹង ឬការរារាំងការធ្វើដំណើរកម្រិតអន្តរជាតិ<br>☐ ការបដិសេធមិនផ្តល់ទិដ្ឋាការសម្រាប់ការធ្វើដំណើរ<br>☐ ការចាប់បញ្ជូនត្រឡប់មកវិញ<br>☐ ផ្សេងទៀត ________ |
| | VIII. ការមិនទទួលស្គាល់ការរំលោភបំពាន និងនិទណ្ឌភាព<br>សូមពិពណ៌នាខាងក្រោម៖<br>________ |

| | |
|---|---|
| ៣. តើអ្នកគិតថានរណាជាជនប្រព្រឹត្ត? | អ្នកដើរតួនាទីរបស់រដ្ឋ (ឧ. នគរបាល ឬមន្ត្រីជម្រុញការអនុវត្តច្បាប់ យោធា មន្ត្រីរដ្ឋាភិបាល) សូមបញ្ជាក់៖ |
| | អ្នកដើរតួនាទីមិនមែនជារបស់រដ្ឋ (ឧ. ក្រុមពាក់កណ្តាលយោធា ក្រុមបងធំឧក្រិដ្ឋជន កម្លាំងសន្តិសុខឯកជន សាជីវកម្ម) សូមបញ្ជាក់៖ |

| | |
|---|---|
| ៣. តើអ្នកគិតថានរណាជាជនប្រព្រឹត្ត? | មិនដឹង (ឧ. ពោលគឺមិនអាចដឹងច្បាស់ ឬកំណត់បានអំពីអត្តសញ្ញាណរបស់ជនប្រព្រឹត្ត) សូមបញ្ជាក់៖ |
| | ផ្សេងទៀត៖ (ឧ. ដៃគូ សមាជិកគ្រួសារ សម្ព័ន្ធមិត្តគួរជាទីទុកចិត្ត) សូមបញ្ជាក់៖ |

| | |
|---|---|
| ៤. តើស្ថានភាពនេះកើតឡើងនៅពេលណា និងដោយសារហេតុអ្វី? តើព្រឹត្តិការណ៍ ឬស្ថានភាពអ្វីដែលបានញ៉ាំងឱ្យអ្នក ឬអង្គការរបស់អ្នកដាក់ពាក្យស្នើសុំនេះ? | |

UAF A&P | កម្មវិធីការផ្ដល់ហិរញ្ញប្បទានឆ្លើយតបរហ័ស

**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

| | |
|---|---|
| ៥. តើអ្នក ឬអង្គការ/បណ្ដាញ/សហគមន៍របស់អ្នកមានផែនការសន្តិសុខ ផែនការការពារ ឬ ផែនការសុខុមាលភាពឬទេ? (សូមពិពណ៌នាដោយសង្ខេបថាតើអ្នកកំពុងអនុវត្តផែនការនេះដោយរបៀបណា)។ | |

៦. សូមធ្វើការគូរនូវចំណុចខាងក្រោមសម្រាប់សកម្មភាពជាក់លាក់ដែលស្នើសុំក្នុងការកាត់បន្ថយហានិភ័យ និងការគំរាមកំហែងដែលអ្នកកំពុងជួបប្រទះ ។ សូមធ្វើការបញ្ជាក់ប្រសិនបើអ្នកកំពុងរួមបញ្ចូលទាំងសមាជិកគ្រួសារ/អ្នកកំដរនៅក្នុងយុទ្ធសាស្ត្ររបស់អ្នក ។

- ☐ សន្តិសុខឌីជីថល
- ☐ ការជម្លៀសចេញ/ការផ្លាស់ទីតាំង (ឧ. មានដូចជាថ្លៃធ្វើដំណើរ ថ្លៃឈ្នួលផ្ទះ ការចំណាយក្នុងការរស់នៅ/ការផ្លាស់ទីតាំងជាបណ្ដោះអាសន្នសម្រាប់អ្នកការពារសិទ្ធិ/ឬក្រុមគ្រួសាររបស់គាត់)
- ☐ ការគាំទ្រសម្រាប់គ្រួសារ៖
- ☐ ជំនួយផ្នែកច្បាប់
- ☐ ការគាំទ្រពេលស្ថិតក្នុងការឃុំឃាំង
- ☐ ការថែទាំវេជ្ជសាស្ត្រ/ការព្យាបាល
- ☐ សុខុមាលភាព និងការការថែទាំខ្លួនឯង (ឧ. ការប្រឹក្សាយោបល់សម្រាប់ករណីការប៉ះទង្គិចធ្ងន់ធ្ងរ/ការប្រឹក្សាយោ
- ☐ សកម្មភាពដើម្បីបង្កើតផែនការ ឬវិធានការសម្រាប់កិច្ចការពារបុគ្គល និង/ឬកិច្ចការពារជាសមូហភាព និងសុខុមាលភាព
- ☐ សន្តិសុខក្នុងការធ្វើដំណើរ
- ☐ ហេដ្ឋារចនាសម្ព័ន្ធសន្តិសុខ (ឧ. មានដូចជាកាមេរ៉ាវីដេអូ ប្រព័ន្ធកណ្ដឹងរោទិ៍ របង ច្រកទ្វារ ប្រព័ន្ធសន្តិសុខតាមអនឡាញ។ល។)
- ☐ បុគ្គលិកសន្តិសុខមិនមានប្រដាប់អាវុធ
- ☐ ផ្សេងទៀត

| | |
|---|---|
| ៧. តើអ្នកកំពុងស្នើសុំការផ្ដល់មូលនិធិសម្រាប់សេចក្ដីត្រូវការផ្នែកសុខុមាលភាពផ្សេងទៀតដែលពុំបានរាយឈ្មោះខាងលើឬទេ?<br><br>ប្រសិនបើឆ្លើយ ចាស សូមពិពណ៌នា ប្រសិនបើឆ្លើយ ទេ សូមរំលងសំណួរនេះ | |

| | |
|---|---|
| ៨. តើសកម្មភាពដែលត្រូវបានស្នើឡើងនេះមានក◌្បខណ្ឌពេលវេលាយ៉ាងដូចម◌្ច? | |
| ៩. តើអ្នក ឬអង្គការរបស់អ្នក ឬបណ្តាញ/សហគមន៏របស់អ្នកគ្រោងអនុវត្តសកម្មភាពទាំងអស់នេះដោយរបៀបណា? សូមពិពណ៌នាដោយសង◌្ខប | |
| ១០. ប◌្រសិនបើទទួលបានមូលនិធិ តើអ្នកសង្ឃឹមថានឹងបានទទួលលទ្ធផលអ្វីខ្លះ? (សូមពិពណ៌នាថាតើមានការផ្លាស់ប្តូរអ្វីខ្លះដែលអ្នករំពឹងចង់សម◌្រេចបាននៅកម្រិតបុគ្គល កម្រិតអង្គការ ឬបណ្តាញ/សហគមន៍) | |

UAF A&P | កម្មវិធីការផ្តល់ហិរញ្ញប្បទានឆ្លើយតបរហ័ស

**ការដាក់ពាក្យស្នើសុំហិរញ្ញប្បទានសន្តិសុខ និងសុខុមាលភាព**

## IV. សំណើសុំថវិកា

| | |
|---|---|
| ១. តើសំណើសុំមានទឹកប្រាក់ចំនួនប៉ុន្មាន? សូមបញ្ជាក់ប្រភេទរូបិយប័ណ្ណដែលអ្នកកំពុងប្រើប្រាស់។ | |

២. តើប្រាក់នេះនឹងត្រូវយកទៅប្រើប្រាស់ដោយរបៀបណា?សូមផ្តល់ថវិកាលើមុខចំណាយនីមួយៗដោយប្រើប្រាស់តារាងខាងក្រោម។
សម្គាល់៖ **UAF A&P** ផ្តល់ហិរញ្ញបទានក្នុងទឹកប្រាក់រហូតដល់ ៥ ០០០ ដុល្លារអាមេរិកតែប៉ុណ្ណោះ។

| មុខចំណាយក្នុងថវិកា | ថ្លៃចំណាយ<br>ប្រភេទរូបិយប័ណ្ណ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |

| | |
|---|---|
| ៣. ក្រៅពីស្វែងរកការផ្តល់មូលនិធិពី UAF A&P តើមានប្រភពគាំទ្រណាផ្សេងទៀតសម្រាប់ការផ្តួចផ្តើមគំនិត ឬសកម្មភាពនេះ? | |

## V. ការរក្សាការសម្ងាត់

| | |
|---|---|
| តើអ្នកចង់ឱ្យការស្នើសុំនេះត្រូវរក្សាជាការសម្ងាត់ឬទេ? | ○ ចាស ○ ទេ<br>ប្រសិនបើអ្នកគូសយកចម្លើយ “ចាស” UAF A&P នឹងមិនបើកបង្ហាញឈ្មោះបុគ្គល និងព័ត៌មានទំនាក់ទំនងទៅកាន់ភាគីណាមួយនៅក្រៅពីអង្គការរបស់យើងឡើយ (លើកលែងតែក្នុងអំឡុងពេលដំណើរការអនុម័តរបស់យើងប៉ុណ្ណោះ ដោយហេតុថា យើងត្រូវពិគ្រោះយោបល់ជាមួយទីប្រឹក្សារបស់ UAF A&P និងបុគ្គលទំនាក់ទំនងដែលយើងទុកចិត្ត)។ |